News Release

ក្រសួងការងារសហរដ្ឋអាមេរិក | ថ្ងៃទី 18 ខែតុលា ឆ្នាំ 2016 BOS 2016-166K

ក្រសួងការងារអាមេរិកបានប្តឹងក្រុមហ៊ុនកែច្នៃត្រីងសមុទ្រ *Gloucester,* **ទីភ្នាក់ងារស្វែងរកការងារឡូវ៉ដលើកម្មវិធីមានការសំណងជាប្រាក់ឈ្នួលយ៉ាងហោចណាស់** *272* **ពាន់ដុល្លារអាមេរិក និងផ្ទេរជំងឺចិត្តសម្រាប់បុគ្គលិក** *55* **នាក់**

ក្រុមហ៊ុន Intershell International Corp., ក្រុមហ៊ុន Ultimate Advance Corp. *បានជំពាក់*

កម្មករប្រាក់ឈ្នួលទាប កម្មករដងវ្រកោះ ផ្ញើឯកសារក្នុងភ្លាយ កាត់ប្រាក់ខែដោយមិនសមរម្យ

ជ្រលុង - ក្រសួងការងារសហរដ្ឋអាមេរិកកំពុងប្តឹងក្រុមហ៊ុន Gloucester ដែលជាក្រុមហ៊ុនអាជីវកម្មកែច្នៃ ផ្ទេរជ្រុង និងចែកចាយត្រីងសមុទ្រ ឡូវ៉ដលីទីភ្នាក់ងារស្វែងរកការងារ បណ្តោះអាសន្ន និងក្រុមហ៊ុនផ្តល់សេវាវៀបចំបញ្ជីលើកប្រាក់ខែសម្រាប់កម្មករបណ្តោះអាសន្នសម្រាប់តែក្រុមហ៊ុននេះ និងម្ចាស់កម្មសិទ្ធិនីមួយរនៃក្រុមហ៊ុនទាំងនេះពីរចំពាក់ កម្មករប្រាក់ឈ្នួលទាប 55 នាក់ ផ្ញើឯកសារក្នុងភ្លាយ និងធ្វើការកាត់ប្រាក់ខែមិនសមរម្យពីកម្មករមួយចំនួន។

ការស៊ើបអង្កេតដែលធ្វើឡើងដោយផ្នែកប្រាក់ឈ្នួល និងការងារគិតម៉ោង Wage and Hour Division របស់ក្រសួងនេះ បានរកឃើញថា ក្រុមហ៊ុន Intershell International Corp និងម្ចាស់ក្រុមហ៊ុនមានឈ្មោះថា Yibing Gao-Rome និង Monte Rome និងក្រុមហ៊ុន Ultimate Advance Corp និងម្ចាស់ក្រុមហ៊ុនមានឈ្មោះថា Phalla Chhit ដែលបានមួយមានកម្មករបានរំលោភលើលក្ខខណ្ឌបង្គរម៉ោង និងការអត្សាកំណត់ត្រានៃច្បាប់ស្តីពីស្តង់ដារការងារប្រកបដោយយុត្តិធម៌ (Fair Labor Standards Act)។

ក្នុងពាក្យបណ្តឹងនេះ ក្រសួងនេះបានចោទប្រកាន់ថា ក្រុមហ៊ុន Intershell និងម្ចាស់ក្រុមហ៊ុននេះចាប់តាំងពីខែកុម្ភៈ ឆ្នាំ 2013 និងក្រុមហ៊ុន Ultimate និងម្ចាស់ក្រុមហ៊ុននេះ ចាប់តាំងពីខែមេសា ឆ្នាំ 2015៖

- មិនបានបើកប្រាក់បន្ថែមម៉ោងទៀងទាត់រយៈ 55 បុគ្គលិកនាក់ដែលបានកាត់សម្ពាត និងផ្ទេរជ្រុងត្រីងសមុទ្រនៅពេលពួកគេបានធ្វើការលើសពី 40 ម៉ោងក្នុងអំឡុងពេលសប្តាហ៍ធ្វើការងារ រួមទាំងកម្មករដែលធ្វើការស៊ីប្រាក់ឈ្នួលគិតតាមម៉ោង និងកម្មករដែលធ្វើការស៊ីប្រាក់ឈ្នួលគិតតាមទំហំការងារ។
- មិនបានរក្សាកំណត់ត្រាគ្រប់ត្រាន់ និងត្រឹមត្រូវអំពីម៉ោងធ្វើការងាររបស់បុគ្គលិកទាំងអស់។
- ផ្តល់ឯកសារបញ្ជីបើកប្រាក់ខែមិនត្រឹមត្រូវទៅឱ្យក្រុមអ្នកស៊ើបអង្កេតនៃផ្នែកនេះ។
- កាត់ប្រាក់ខែពីបុគ្គលិកមួយចំនួនសម្រាប់បង់ថ្លៃសម្ភាតឯកសណ្ឋានរបស់ពួកគេ។

ក្រសួងនេះកំពុងស្នើសុំឱ្យតុលាការកាត់ក្តីឲ្យជនជាប់ចោទក្នុងក្រុមហ៊ុន Intershell ទទួលខុសត្រូវបើកប្រាក់ឈ្នួលបង្គ្រប់ និងទូទាត់ថ្លៃជំងឺចិត្តយ៉ាងហោចណាស់ 272,000 ដុល្លារ ។ ក្នុងចំនួនទឹកប្រាក់សរុបនោះ ជនជាប់ចោទក្នុងក្រុមហ៊ុន Ultimate រួមគ្នាទទួលខុសត្រូវបង់ប្រាក់ប្រមាណជា 116,000ដុល្លារ។ ក្រសួងនេះក៏ស្វែងរកវិធីការបង្ការ និងទប់ស្កាត់នូវជនជាប់ចោទទាំងអស់ជាអចិន្ត្រៃយ៍មិនឲ្យរំលោភបំពានលើច្បាប់ FLSA ក្នុងពេលអនាគត។

លោក Carlos Mato នាយកផ្នែកប្រាក់ឈ្នួល និងការងារគិតតាមម៉ោងប្រចាំរដ្ឋ Massachusetts បានមានប្រសាសន៍ថា៖ "ករណីនេះទាក់ទងកម្មករប្រាក់ឈ្នួលទាបដែលងាយរងគ្រោះនៃការកេងប្រវ័ញ្ច។ បណ្តាឧស្សាហកម្មកែច្នៃត្រីងសមុទ្រជាញឹកញាប់ប្រើប្រាស់ទីភ្នាក់ងារបណ្តោះអាសន្នដើម្បីផ្តល់កម្មករ និងការរៀបចំនោះជួនកាលអាចត្រូវបានប្រើដោយនិយោជកដើម្បីព្យួយមមជ្ឈិសវាងនូវកាតព្វកិច្ចរបស់ខ្លួននៅក្រោមច្បាប់ស្តីពីស្តង់ដារការងារប្រកបដោយយុត្តិធម៌ ។ ការបង្កើតការងារមួយគ្នា និងការធ្វើឲ្យក្រុមហ៊ុនមេទទួលខុសត្រូវចំពោះការរំលោភបំពានច្បាប់ FLSA គឺជួយលើកកម្ពស់ការយល់ដឹងពីការទទួលខុសរបស់ពួកគេ និងធ្វើឲ្យគ្រប់ភាគីទាំងអស់ទទួលខុសត្រូវចំពោះអនុវត្តតាមច្បាប់។ និយោជកត្រូវតែយកចិត្តទុកដាក់ចំពោះករណីនេះ និងផ្ទេរផ្តើមចាត់វិធានការកែប្រែនៅពេលដែលចាំបាច់ដើម្បីធានាថា កម្មករបស់ខ្លួនត្រូវបានបើកប្រាក់ខែបាន សមរម្យ។"

លោក Michael Felsen មេធាវីក្នុងតំបន់ New England នៃក្រសួងនេះបានមានប្រសាសន៍ថា៖ "ករណីនេះបង្ហាញ 'កន្លែងការងារយ៉ាងកាក់ ' ជាទីកន្លែងការងារដែលចំនាក់ចំនងការងារវាងកម្មករ និងក្រុមហ៊ុនអាជីវកម្មនេះទទួលបានអត្ថប្រយោជន៍ពីការងារបស់ពួកគេបានយ៉ែកបាក់ឃ្យាះក្រុមហ៊ុនបានចុះកិច្ចសន្យាសកម្មភាពនានាទៅឲ្យទីភ្នាក់ងារស្វែងរកបុគ្គលិក ជាញឹកញាប់ដើម្បីដៀសវាងចំណុល និងដើម្បីកាត់បន្ថយការចំណាយ"។ លោកបានបន្ថែមទៀតថា៖ "ក្នុងកិច្ចសន្យាទាំងនេះ ជាញឹកញាប់កម្មករមិនត្រូវបានផ្តល់ដោយមិនស្របច្បាប់នូវប្រាក់ឈ្នួលពេញលេញដែលពួកគេមានសិទ្ធិទទួលបាន។ ក្នុងករណីនេះ ទាំងក្រុមហ៊ុនដែលប្រើប្រាស់កម្លាំងពលកម្មក្នុងកិច្ចសន្យា និងភ្នាក់ងារស្វែងរកបុគ្គលិកដែលផ្តល់កម្មករ មានការទទួលខុសត្រូវក្នុងនាមនិយោជកដែលសមតាមច្បាប់ និងត្រូវស្ថិតក្រោមចំណាត់ការនៃការអនុវត្តតាមច្បាប់ប្រសិនបើពួកគេមិនបានធ្វើ។"

ការិយាល័យមណ្ឌលបម្រុងនៃផ្នែកនេះបានស៊ើបអង្កេតករណីនេះ ខណៈដែលមេធាវីជំនុំជម្រះជាន់ខ្ពស់លោក James Glickman និងមេធាវីជំនុំជម្រះលោក Sheila Gholkar នៅក្នុងការិយាល័យមេធាវីបម្រុងបានដាក់ពាក្យបណ្តឹង។

U.S. Department of Labor news materials are accessible at http://www.dol.gov. The department's Reasonable Accommodation Resource Center converts departmental information and documents into alternative formats, which include Braille and large print. For alternative format requests, please contact the department at (202) 693-7828 (voice) or (800) 877-8339 (federal relay).

ចំណេះព័ត៌មានបន្ថែមអំពីច្បាប់ស្តីពីស្តង់ដារការងារប្រកបដោយយុត្តិធម៌ និងច្បាប់សហព័ន្ធផ្សេងទៀតស្តីពីប្រាក់ឈ្នួល សួមទូរស័ព្ទដោយឥតគិតថ្លៃទៅកាន់ផ្នែកប្រាក់ឈ្នួល និងការងារគិតតាមម៉ោង តាមរយៈលេខ 866-4US-WAGE (487-9243)។ ក៏អាចទទួលមើលព័ត៌មានបន្ថែមតាមគេហទំព័រ៖ http://www.dol.gov/whd ។

# # #

Perez v. Intershell International Corp., Yibing Gao-Rome, Monte Rome; Ultimate Advance Corp., Phalla Chhit.

លេខនាតីវិធានការស៊ីវិល៖ 1:16-cv-11999

ទំនាក់ទំនងប្រព័ន្ធផ្សព្វផ្សាយ៖

Ted Fitzgerald, 617-565-2075, fitzgerald.edmund@dol.gov
James C. Lally, 617-565-2074, lally.james.c@dol.gov

លេខចេញផ្សាយ៖ 16-2014-BOS

U.S. Department of Labor news materials are accessible at http://www.dol.gov. The department's Reasonable Accommodation Resource Center converts departmental information and documents into alternative formats, which include Braille and large print. For alternative format requests, please contact the department at (202) 693-7828 (voice) or (800) 877-8339 (federal relay).